## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
និងអតីតយុទ្ធជន
លេខ :...757 សកង

## ប្រកាស
## ស្តីពីការបង្កើត មជ្ឈមណ្ឌលជាតិនៃជនពិការ

### រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆការ ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២.នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះក្រឹត្យលេខ ជស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន
- ពិនិត្យឃើញការចាំបាច់របស់ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន

# សំរេច

ប្រការ១ : បង្កើតមជ្ឈមណ្ឌលជាតិនៃជនពិការ ដែលមានទីតាំងនៅ អាគារលេខ ៣ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ។ មជ្ឈមណ្ឌលជាតិនៃជនពិការ អាចបង្កើតសាខារបស់ខ្លួនបានទៅតាមសេចក្តីត្រូវការចាំបាច់នៅក្នុងខេត្តផ្សេងៗ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ២ : មជ្ឈមណ្ឌលជាតិនៃជនពិការ ត្រូវបានដឹកនាំ ដោយក្រុមប្រឹក្សាភិបាលដែលមានសមាសភាព មកពី ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន បណ្តាក្រសួងនានា និង អង្គការក្រៅរដ្ឋាភិបាល ដែលមានការចាប់អារម្មណ៍លើបញ្ហាពិការភាព ។ កិច្ចប្រតិបត្តិការ របស់ មជ្ឈមណ្ឌលជាតិនៃជនពិការត្រូវដំណើរការ ដោយនាយកប្រតិបត្តិមួយនាក់ ដែលត្រូវបានជ្រើសរើស និងតែងតាំងដោយក្រុមប្រឹក្សាភិបាល ។ នាយកប្រតិបត្តិជាអ្នកទទួលខុសត្រូវទៅលើកិច្ចប្រតិបត្តិការរបស់មជ្ឈមណ្ឌលជាតិនៃជនពិការ ។

ប្រការ៣: មជ្ឈមណ្ឌលជាតិនៃជនពិការត្រូវបង្កើតនូវលក្ខខ័ន្តិកៈ គោលបំណងនិងទិសដៅច្បាស់លាស់ដើម្បីដឹកនាំការងារដោយឯករាជ្យ និង ប្រកបដោយប្រសិទ្ធភាពតាមគោលការណ៍របស់ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ។ កិច្ចការដ៏សំខាន់របស់មជ្ឈមណ្ឌលជាតិនៃជនពិការ គឺធ្វើយ៉ាងណាដើម្បីផ្តល់សេវា ស្តារលទ្ធភាពពលកម្ម បង្កើនសេដ្ឋកិច្ច រកការងារ និងផ្តល់ការងារជូនជនពិការ ដើម្បីអោយបងប្អូនពិការមានការ រស់នៅប្រកបដោយសេចក្តី ថ្លៃថ្នូរ មានឱកាសពេញលេញចូលរួមគ្រប់សកម្មភាពនៅក្នុងសង្គមកម្ពុជា ។

ប្រការ៤: រាល់ការចំណាយ និងមធ្យោបាយបំរើការងាររបស់មជ្ឈមណ្ឌលជាតិនៃជនពិការ ស្ថិតនៅក្នុងបន្ទុករបស់មជ្ឈមណ្ឌលជាតិនៃជនពិការ ។

ប្រការ៥: រៀងរាល់ចុងត្រីមាសម្តង មជ្ឈមណ្ឌលជាតិនៃជនពិការ ត្រូវធ្វើរបាយការណ៍ចំណូលចំណាយ. របាយការណ៍ស្តីពីប្រសិទ្ធិភាពនិងលទ្ធផលការងារ ជូនក្រសួងដើម្បី ជ្រាបជាព័ត៌មាន ។

ប្រការ៦: ក្នុងករណីចាំបាច់ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន មានសិទ្ធិផ្លាស់ប្តូរ សមាស-ភាពក្រុមប្រឹក្សាភិបាល និងរៀបចំក្រុមប្រឹក្សាភិបាលថ្មី ។

ប្រការ៧: នាយកនៃនាយកដ្ឋានស្តារលទ្ធភាពពលកម្ម នាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ និងផ្គត់ផ្គង់ និងនាយកដ្ឋានពាក់ព័ន្ធ និងអធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជនខេត្ត-ក្រុង មានភារៈ អនុវត្តន៍ប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ១៩៩៧

រដ្ឋលេខាធិការ

ស៊ុយ_សែម